ជំនាញការងារ

អ្នកអាចសម្រេចបាន ៖

- បទពិសោធន៍ច័ះពាល់ផ្ទាល់
- ភាពស្គាត់ជំនាញខាងកុំព្យូទ័រ
- ពាក្យពេចន៍វេជ្ជសាស្ត្រ
- ជំនាញទំនាក់ទំនង
- ជំនាញសរសេរ
- ការគ្រប់គ្រងពេលវេលា

ការបណ្តុះបណ្តាល

ឧទាហរណ៍ខ្លះៗនៃការបណ្តុះបណ្តាល ៖

- បច្ចេកវិទ្យាមុខជំនាញ
- វិជ្ជាជីវៈវេជ្ជសាស្ត្រ
- ពាណិជ្ជកម្មឧស្សាហកម្ម
- ពាណិជ្ជកម្មរថយន្ត
- ផ្នែកទន់ និងការរចនាកុំព្យូទ័រ
- សេវាកម្មសង្គម និងមនុស្ស

ជាអ្នកដឹកនាំដ៏ខ្លាំងរបស់
គ្រួសារអ្នក ។
បង្ហាញភូនរបស់អ្នកនូវ
កម្លាំង នៃ
ការអប់រំ និងជម្រើសវិជ្ជមាន
ដែលវានាំមក ។

ផ្នែកសេវាកម្មសហគមន៍
រដ្ឋបាលសេវាកម្មសេដ្ឋកិច្ច
PO Box 45440
Olympia, WA 98504-5440

Washington State Department of Social & Health Services

Transforming lives

DSHS 22-1579 CA (11/14)

ការអប់រំឲ្យផលមកវិញ!

និយាយជាមួយអ្នកគ្រប់គ្រងសំណុំរឿង WorkFirst
របស់អ្នកអំពីជម្រើសការអប់រំរបស់អ្នក ។

Washington State Department of Social & Health Services

Transforming lives

តើខ្ញុំទទួលបានការងារ ល្អយ៉ាងដូចម្តេច?

ការទៅរៀនរយៈពេលមួយឆ្នាំអាចធ្វើឲ្យមានភាពខុសគ្នាច្រើន ។ វិញ្ញាបនបត្ររយៈពេលមួយឆ្នាំអាចឲ្យអ្នកមានការងារដែលមានប្រាក់ចំណូលគ្រប់គ្រាន់ដើម្បីថែទាំគ្រួសាររបស់អ្នក ។

មានកម្មវិធីអប់រំដើម្បីជួយអ្នកទទួលបានការងារដែលអ្នកចង់បាន ។ បើអ្នកទទួលជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារក្រីក្រ (TANF) អ្នកអាចចូលរៀនដោយគិតគិតថ្លៃដែលនឹងជួយអ្នកទទួលបានការងារ ។ កម្មវិធីដែលទាំឲ្យទទួលវិញ្ញាបនបត្រ និងការងារ អាចត្រូវបានបញ្ចូលក្នុងគម្រោងការទទួលខុសត្រូវផ្ទាល់ខ្លួន (IRP) របស់អ្នក ។ មហាវិទ្យាល័យក្នុងតំបន់នឹងជួយអ្នកដាក់ពាក្យសម្រាប់ជំនួយហិរញ្ញវត្ថុដែលអ្នកអាចត្រូវការសម្រាប់កម្មវិធីផ្សេង ។

មិនទាន់មានសញ្ញាបត្រទុតិយភូមិ ឬសញ្ញាបត្រសមមូល? ពួកយើងអាចជួយ និងវាជាជំហានដំបូងឆ្ពោះទៅការទទួលបានការងារដែលនឹងថែទាំគ្រួសាររបស់អ្នក ។

ចាប់អារម្មណ៍ក្នុងការអប់រំ?

និយាយជាមួយអ្នកគ្រប់គ្រងសំណុំរឿង WorkFirst របស់អ្នកដើម្បីដឹងថាការអប់រំអាចជាផ្នែកនៃគម្រោងការទទួលខុសត្រូវផ្ទាល់ខ្លួន (IRP) របស់អ្នក ។

តើខ្ញុំអាចទទួលបានប្រាក់ឈ្នួលបន្ថែមយ៉ាងដូចម្តេច?

បន្តការសិក្សារបស់អ្នកខណៈដែលអ្នកកំពុងធ្វើការដើម្បីបង្កើនប្រាក់ចំណូលរបស់អ្នក ។ ការទទួលការអប់រំ អ្នកត្រូវតែឯករាជ្យគឺជាជំហានដំបូងក្នុងការទៅដល់គោលដៅរបស់អ្នក ។

Cathy មិនបានធ្វើការរយៈពេលពីរឆ្នាំ និងមិនបានចូលរៀនរយៈពេលដប់ឆ្នាំ ។ ជាម្តាយដែលមានកូនពីរ គាត់ព្រួយបារម្ភអំពីការត្រឡប់ទៅសាលាវិញ ប៉ុន្តែដឹងថាវាជាផ្លូវតែមួយគត់ដែលគាត់នឹងអាចទទួលបាន ការងារល្អលើសពីការងារដែលមានប្រាក់ឈ្នួលអប្បបរមា ។

Cathy បានបញ្ចប់វិញ្ញាបនបត្រគ្រប់គ្រងមុខជំនួញនៅមហាវិទ្យាល័យសហគមន៍ក្នុងតំបន់របស់គាត់ក្នុងរយៈពេលមួយឆ្នាំខណៈដែលកំពុងទទួលប្រាក់ជំនួយ TANF ដើម្បីជួយគ្រួសាររបស់គាត់ ។

ឥឡូវ Cathy កំពុងធ្វើការជាភ្នាក់ងារលក់ធានារ៉ាប់រង ។ គាត់ទទួលប្រាក់ចំណូលគ្រប់គ្រាន់ដើម្បីគាំទ្រគ្រួសាររបស់គាត់ដោយគ្មាន TANF ។

Cathy កំពុងបន្តការសិក្សារបស់គាត់ខណៈដែលគាត់ធ្វើការ ។ ថ្នាក់ដែល Cathy បានរៀនសម្រាប់វិញ្ញាបនបត្ររបស់គាត់អាចត្រូវបានប្រើក្នុងការបញ្ចប់សញ្ញាបត្ររដ្ឋបាលមុខជំនួញ ។

តើការងារប្រភេទណាខ្លះដែលខ្ញុំអាចហ្វឹកហ្វាត់បាន?

មហាវិទ្យាល័យទីមួយៗមានកម្មវិធីបណ្តុះបណ្តាលសម្រាប់ការងារដែលមានក្នុងតំបន់ពួកគេ ។ ទាក់ទងមហាវិទ្យាល័យក្នុងតំបន់របស់អ្នកដើម្បីស្វែងយល់ពីកម្មវិធីមួយណាដែលសក្តិសមសមសម្រាប់អ្នក ។ ឧទាហរណ៍ខ្លះនៃកម្មវិធីបណ្តុះបណ្តាលដែលមានជុំវិញរដ្ឋ គឺ ៖

- ការផ្សារពេទ្យ
- ជំនួយការគិលានុបដ្ឋាយិការដែលមានវិញ្ញាបនបត្រ (NAC)
- បច្ចេកវិទ្យាកុំព្យូទ័រ
- ជំនួយការវេជ្ជសាស្ត្រ
- ជំនួយការឱសថ្ឋញ
- ការអប់រំកុមារភាពមុនពេល
- រដ្ឋបាលមុខជំនួញ
- ការទំនាក់ទំនងប្រព័ន្ធផ្សព្វផ្សាយ
- យុត្តិធម៌ព្រហ្មទណ្ឌ
- គណនេយ្យ
- ជួសជុលរថយន្ត
- ត្រៀងយន្ត